ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខៈ ៧៤៨៧៤ ប្រក

# ប្រកាស
## ស្តីពី
## ការកំណត់ចំនួនមុខតំណែងស្នងការរង នាយរងការិយាល័យ អធិការរង មេបញ្ជាការរង នាយរងផ្នែក និងនាយរងប៉ុស្តិ៍នគរបាល ចំណុះស្នងការដ្ឋាននគរបាលរាជធានី ខេត្ត

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២៧៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតអគ្គនាយកដ្ឋានធនធានមនុស្ស ចំណុះក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២៦២ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
- បានឃើញប្រកាសលេខ៤២៨០ ប្រ.ក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
- បានឃើញប្រកាសលេខ៤៣០៨ ប្រ.ក ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ

- បានឃើញប្រកាសលេខ៤៤១២ ប្រ.ក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការកែសម្រួលតួនាទីនិងភារកិច្ចរបស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់
- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

**ប្រការ១ ..**

ប្រកាសនេះកំណត់អំពីចំនួនមុខតំណែងស្នងការរងនគរបាលរាជធានី ខេត្ត នាយរងការិយាល័យ អធិការរងនគរបាលក្រុង ស្រុក ខណ្ឌ មេបញ្ជាការរងវរសេនាតូចនគរបាលការពារព្រំដែនគោក នាយរងផ្នែកនៃការិយាល័យ នាយរងផ្នែកនៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ នាយរងផ្នែកនៃវរសេនាតូចនគរបាលការពារព្រំដែនគោក នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ និងនាយរងប៉ុស្តិ៍នគរបាលការពារព្រំដែនគោក ចំណុះស្នងការដ្ឋាននគរបាលរាជធានី ខេត្ត។

**ប្រការ២ ..**

មុខតំណែងស្នងការរងនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវបានកំណត់ចំនួនដូចខាងក្រោម៖

- ស្នងការរងនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ មានចំនួនចន្លោះពី១៤(ដប់បួន) ទៅ ១៦(ដប់ប្រាំមួយ)រូប
- ស្នងការរងនៃស្នងការដ្ឋាននគរបាលខេត្តជាប់ព្រំដែន មានចំនួនចន្លោះពី១២(ដប់ពីរ) ទៅ ១៤(ដប់បួន)រូប
- ស្នងការរងនៃស្នងការដ្ឋាននគរបាលខេត្តមិនជាប់ព្រំដែន និងស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ មានចំនួនចន្លោះពី១១(ដប់មួយ) ទៅ ១៣(ដប់បី)រូប
- ស្នងការរងនៃស្នងការដ្ឋាននគរបាលខេត្តកែបនិងខេត្តប៉ៃលិន មានចំនួនចន្លោះពី៧(ប្រាំពីរ) ទៅ ៩(ប្រាំបួន)រូប។

ចំពោះស្នងការរងទទួលផែនការងារប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន និងការងារយេនឌ័រ ត្រូវមាន១(មួយ)រូប ជានារី។

**ប្រការ៣ ..**

មុខតំណែងនាយរងការិយាល័យ អធិការរង មេបញ្ជាការរង ត្រូវបានកំណត់ចំនួនដូចខាងក្រោម៖

- នាយរងការិយាល័យ មានចំនួន ៤(បួន)រូប
- អធិការរងនគរបាលខណ្ឌ មានចំនួន ៨(ប្រាំបី)រូប
- អធិការរងនគរបាលក្រុងសៀមរាប និងក្រុងព្រះសីហនុ មានចំនួន ៨(ប្រាំបី)រូប
- អធិការរងនគរបាលក្រុង ស្រុក មានចំនួន ៦(ប្រាំមួយ)រូប
- មេបញ្ជាការរង មានចំនួន ៤(បួន)រូប។

ចំពោះ នាយរងការិយាល័យ អធិការរងនគរបាល និងមេបញ្ជាការរង ត្រូវមាន១(មួយ)រូប ជានារី។

**ប្រការ៤ ..**

មុខតំណែងនាយរងផ្នែកនិងថ្នាក់ប្រហាក់ប្រហែល និងនាយរងប៉ុស្តិ៍នគរបាល ត្រូវបានកំណត់ចំនួនដូចខាងក្រោម៖

- នាយរងផ្នែកចំណុះការិយាល័យនិងថ្នាក់ប្រហាក់ប្រហែល មានចំនួន ២(ពីរ)រូប
- នាយរងផ្នែកចំណុះអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ មានចំនួន២(ពីរ)រូប
- នាយរងផ្នែកចំណុះវរសេនាតូចនគរបាលការពារព្រំដែនគោក មានចំនួន២(ពីរ)រូប
- នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់នៃអធិការដ្ឋាននគរបាលខណ្ឌ មានចំនួន៤(បួន)រូប
- នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់នៃអធិការដ្ឋាននគរបាលក្រុង ស្រុក មានចំនួន៣(បី)រូប
- នាយរងប៉ុស្តិ៍នគរបាលការពារព្រំដែនគោក មានចំនួន២(ពីរ)រូប។

**ប្រការ៥** ..

ការកំណត់ចំនួនមុខតំណែងនេះមិនមានអានុភាពប្រតិសកម្មចំពោះមុខតំណែងរបស់មន្ត្រីនគរបាលជាតិដែលបានតែងតាំងរួចហើយទេ។

**ប្រការ៦** ..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧** ..

អគ្គលេខាធិការ អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានក្រុមប្រឹក្សានីតិកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថលនិងផ្សព្វផ្សាយអប់រំ ប្រធាននាយកដ្ឋានអង្គភាពពាក់ព័ន្ធ និងស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ [illegible] ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមអភិសន្តិបណ្ឌិតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ